**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ១៩៦ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ១៨៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ពីផ្ទៃដីទំហំ២៥ ២៦៩(ពីរម៉ឺនប្រាំពាន់ពីររយហុកសិបប្រាំបួន)ហិកតា មកផ្ទៃដីទំហំ៤៣ ៣៩១(បួនម៉ឺនបីពាន់បីរយកៅសិបមួយ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែងខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ២៥ ២៦៩(ពីរម៉ឺនប្រាំពាន់ពីររយហុកសិបប្រាំបួន)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ១៨៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះឧត្តរ ដែលមានផ្ទៃដីទំហំ១៨ ១២២(មួយម៉ឺនប្រាំបីពាន់មួយរយម្ភៃពីរ)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់
- ការពារសោភណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង សម្រាប់បម្រើដល់ការកម្សាន្ត ការទេស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌មូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់តួនាទីសហគមន៍មូលដ្ឋាននិងវិស័យឯកជន ក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តព្រះវិហារ ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្ដីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

នៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


Google Earth
Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984
1:200,000
0 2.5 5 10 Km

## ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣
## ចំណុចនិយាមកានៃផែនទីតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 483978 | 1522903 | 39 | 504967 | 1496748 | 77 | 489228 | 1500069 |
| 2 | 487921 | 1523327 | 40 | 504527 | 1497837 | 78 | 490223 | 1499799 |
| 3 | 490963 | 1522586 | 41 | 503243 | 1498730 | 79 | 489468 | 1499019 |
| 4 | 493027 | 1519622 | 42 | 502939 | 1500046 | 80 | 488535 | 1498932 |
| 5 | 493927 | 1516924 | 43 | 502272 | 1499240 | 81 | 487087 | 1497510 |
| 6 | 493742 | 1515601 | 44 | 501346 | 1499187 | 82 | 487821 | 1498059 |
| 7 | 494932 | 1514913 | 45 | 500966 | 1497565 | 83 | 488556 | 1497729 |
| 8 | 495986 | 1512318 | 46 | 500522 | 1495890 | 84 | 489409 | 1498116 |
| 9 | 497483 | 1509134 | 47 | 502518 | 1496278 | 85 | 491338 | 1497558 |
| 10 | 500239 | 1508355 | 48 | 501339 | 1495123 | 86 | 492619 | 1498780 |
| 11 | 501142 | 1506515 | 49 | 499497 | 1494329 | 87 | 493348 | 1499334 |
| 12 | 502288 | 1503764 | 50 | 499189 | 1493355 | 88 | 492519 | 1501266 |
| 13 | 505727 | 1503919 | 51 | 499832 | 1491574 | 89 | 492129 | 1503574 |
| 14 | 507829 | 1504389 | 52 | 498864 | 1491574 | 90 | 491561 | 1505196 |
| 15 | 510283 | 1503399 | 53 | 498050 | 1492250 | 91 | 492789 | 1507584 |
| 16 | 508167 | 1501667 | 54 | 496494 | 1491680 | 92 | 491175 | 1509806 |
| 17 | 507415 | 1500594 | 55 | 495949 | 1492484 | 93 | 488132 | 1508907 |
| 18 | 508596 | 1500840 | 56 | 495667 | 1493384 | 94 | 485778 | 1510336 |
| 19 | 509623 | 1500731 | 57 | 495195 | 1494124 | 95 | 484666 | 1511870 |
| 20 | 510372 | 1500457 | 58 | 494145 | 1494556 | 96 | 485037 | 1512770 |
| 21 | 511046 | 1499625 | 59 | 493719 | 1495454 | 97 | 483952 | 1513458 |
| 22 | 512540 | 1498900 | 60 | 492545 | 1496331 | 98 | 481703 | 1513907 |
| 23 | 514250 | 1498129 | 61 | 491277 | 1496309 | 99 | 479322 | 1514040 |
| 24 | 515658 | 1496877 | 62 | 491933 | 1494999 | 100 | 477946 | 1516077 |
| 25 | 514421 | 1495203 | 63 | 491778 | 1493919 | 101 | 480459 | 1516447 |
| 26 | 514057 | 1494027 | 64 | 492015 | 1492540 | 102 | 480274 | 1518829 |
| 27 | 514023 | 1492799 | 65 | 490984 | 1493316 | 103 | 481888 | 1519173 |
| 28 | 512178 | 1492816 | 66 | 490185 | 1495265 | 104 | 483873 | 1520866 |
| 29 | 510797 | 1493152 | 67 | 489493 | 1496550 | 105 | 478025 | 1521633 |
| 30 | 510006 | 1493938 | 68 | 489506 | 1495306 | 106 | 475035 | 1521316 |
| 31 | 508624 | 1493754 | 69 | 487311 | 1495339 | 107 | 472601 | 1523274 |
| 32 | 508399 | 1494811 | 70 | 484809 | 1495303 | 108 | 471966 | 1525999 |
| 33 | 508841 | 1496080 | 71 | 485151 | 1496828 | 109 | 475247 | 1524676 |
| 34 | 509355 | 1496781 | 72 | 485094 | 1498536 | 110 | 477126 | 1523803 |
| 35 | 508200 | 1497525 | 73 | 485928 | 1498719 | 111 | 479269 | 1523300 |
| 36 | 507869 | 1496044 | 74 | 486719 | 1498873 | 112 | 480407 | 1522533 |
| 37 | 506767 | 1495687 | 75 | 487496 | 1499476 | | | |
| 38 | 506379 | 1496266 | 76 | 488082 | 1499302 | | | |